# ភាសាខ្មែរៈកិច្ចការអនុវត្ត

## II. ចូរអានអត្ថបទរួចឆ្លើយនឹងសំណួរៈ

### អំណានៈ ស្រមោលអតីតកាល

យប់នេះ ខ្ញុំគេងមិនលក់សោះខ្ញុំចេះតែស្រមៃទៅដល់អតីតកាលដែលគួរឱ្យឈឺចាប់បំផុត។ ខ្ញុំនៅចាំបាននៅខែកក្កដា ឆ្នាំ១៩៧៧ ខ្ញុំមានអាយុប្រាំបីឆ្នាំ។ ខ្ញុំមានជំងឺហើម ដោយខ្វះជីវជាតិអាហារ។ យប់មួយ ខ្ញុំឃ្លានខ្លាំងពេកមិនអាចទ្រាំបាន ក៏លួចរត់ទៅភូមិក្រែងបានអ្វីបន្តិចបន្តួចហូបឱ្យមានកម្លាំង។ ទៅដល់មុខផ្ទះ ដោយសារពន្លឺព្រះចន្ទខ្ញុំឃើញក្រូចថ្លុងនៅសល់បីផ្លែ។ ពេលនោះនៅក្នុងខ្ទម ម្ដាយឪពុកខ្ញុំសម្រាន្តលក់ស្ងាត់ឈឹង។ ខ្ញុំចូលទៅដាស់គាត់ ហើយសូមឱ្យគាត់បេះផ្លែក្រូចឱ្យខ្ញុំហូប។ ឪពុកខ្ញុំអាណិតខ្ញុំពេកក៏ដាច់ចិត្តប្រថុយលីតម្កក់ដើរទៅកាន់ដើមក្រូចទាំងភិតភ័យបំផុត។ ពុកថ្ពក់ផ្លែក្រូចថ្មមៗ។ ផ្លែក្រូចធ្លាក់ខ្ទុកដូចចិត្ត។ ខ្ញុំឃើញគាត់ឱនរើសផ្លែក្រូច ស្រាប់តែកងឈ្លបមិនដឹងជាមកដល់ពីរថ្មើរណាចាប់ដៃគាត់ជាប់ហើយស្រែកដាក់គាត់ៈ «មិត្តឯងក្បត់! យើងរកឃើញខ្មាំងហើយ!»។ ពួកវាក៏ចាប់ចងពុកបណ្ដើរយកទៅ។ ពេលនោះខ្ញុំភ័យពេករត់យករួចខ្លួនភ្លេចគិតអ្វីទាំងអស់។ ព្រឹកស្អែកឡើងខ្ញុំលឺគេខ្សឹបគ្នាថា កងឈ្លបបានយកឪពុកម្ដាយ និងប្អូនស្រីខ្ញុំទៅសម្លាប់អស់ហើយ។

នេះហើយជារឿង ដែលធ្វើឱ្យខ្ញុំចងចាំមិនដែលភ្លេច។ ខ្ញុំសូមឱ្យខ្មែរជំនាន់ក្រោយចេះអត់ឱនអធ្យាស្រ័យគ្នា ហើយបែងចែកមិត្ត និងសត្រូវឱ្យបានច្បាស់ និងរួបរួមសាមគ្គីគ្នាកសាងមាតុភូមិឱ្យបានរុងរឿង។

## II. ចូរផ្គូផ្គងពាក្យ កន្សោមពាក្យ ទៅថ្នាក់ពាក្យ សេចក្ដីពន្យល់ឱ្យបានជាចម្លើយត្រឹមត្រូវៈ

| ពាក្យ កន្សោមពាក្យ | ថ្នាក់ពាក្យ និងសេចក្ដីពន្យល់ |
|---|---|
| ១. ខ្ទម | -(កិ.)៖ ខំកាត់ចិត្តធ្វើដោយផ្សងព្រេងសំណាង,ហ៊ានស៊ូមិនញញើតសេចក្ដីវិនាស។ |
| ២. ប្រថុយ | -(ន.)៖ សេចក្ដីព្រមព្រៀង ដំណើរស្រុះគ្នា។ |
| ៣. កងឈ្លប | -(ន.)៖ ជនមួយក្រុមដែលមាននាទីលបស្ដាប់,លបមើលរាល់សកម្មភាពផ្សេងៗ។ |
| ៤.សាមគ្គី | -(ន.)៖ ផ្ទះតូចជាទីសម្រាប់សំចត។ |

LIVEWORKSHEETS

III. **ចូរវេវចនសព្ទ(ពាក្យន័យដូច) នឹងពាក្យ «គេង ,ឃ្លាន»ឱ្យបានត្រឹមត្រូវ៖**

**១. គេង:** ដេក សម្រាក សម្រាន្ត និទ្រា អង្គុយ ផ្ទំ

**២. ឃ្លាន:** ហេវ អស់កម្លាំង ស្រេក ឃ្លានណាយ

IV. **ចូរជ្រើសរើសថ្នាក់ពាក្យ និងសេចក្ដីពន្យល់នៃសទិសសព្ទ(ពាក្យសូរដូច)នឹងពាក្យ «ក៏»៖**

**១. ក៏៖** ..........................................................................................................

**២. ក៖** ..........................................................................................................

**៣. ករ៖** ..........................................................................................................

V. **ចូរឆ្លើយនឹងសំណួរខាងក្រោមឱ្យបានត្រឹមត្រូវ៖**

១. តើរឿងនេះកើតឡើងនៅក្នុងសម័យកាលណា?

..........................................................................................................

..........................................................................................................

២. ចំពោះរឿងនេះ តើអ្នកមានអារម្មណ៍យ៉ាងណាដែរ?

..........................................................................................................

..........................................................................................................

..........................................................................................................

៣. តើក្នុងអត្ថបទអំណានខាងលើបានផ្ដល់នូវគំនិតអប់រំអ្វីខ្លះ?

..........................................................................................................

..........................................................................................................

..........................................................................................................

LIVEWORKSHEETS